## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ៥៧២ មស.ស.ជ.ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបោះពុម្ពតារាងទូទាត់បៀវត្ស អាណត្តិបើកប្រាក់ និងការបើកផ្តល់ប្រាក់បៀវត្ស ជូនមន្ត្រីរាជការស៊ីវិលសម្រាប់ខែមេសា-ឧសភា ឆ្នាំ២០១៦

យោងសារាចរលេខ០១ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល។

ក្រសួងមុខងារសាធារណៈ មានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ឯកឧត្តមអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត និង លោក លោកស្រីប្រធានមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត មេត្តាជ្រាបថា ក្នុងគោលបំណងចូលរួមអនុវត្តឱ្យបានសម្រេចនូវខ្លឹមសារនៃសារាចរដូចមានយោងខាងលើ ក្រសួងមុខងារសាធារណៈ សូមដាក់ចេញនូវសេចក្តីជូនដំណឹងសម្រាប់អនុវត្តនិងសហការអនុវត្តដូចខាងក្រោម៖

- សម្រាប់ការបើកផ្តល់បៀវត្សប្រចាំខែមេសា ឆ្នាំ២០១៦ ជូនមន្ត្រីរាជការស៊ីវិលឱ្យបានមុនថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦ ក្រសួងមុខងារសាធារណៈ នឹងរៀបចំបោះពុម្ពតារាងទូទាត់បៀវត្សរបស់មន្ត្រីរាជការស៊ីវិលប្រចាំខែមេសា ឆ្នាំ២០១៦ ដោយផ្អែកលើទិន្នន័យដែលមានក្នុងតារាងទូទាត់បៀវត្សរបស់មន្ត្រីរាជការស៊ីវិលប្រចាំខែមីនា ឆ្នាំ២០១៦ជាគោល នៅសប្តាហ៍ទី៤នៃខែមីនា ឆ្នាំ២០១៦
- សម្រាប់ការបើកផ្តល់បៀវត្សប្រចាំខែឧសភា ឆ្នាំ២០១៦ ក្រសួងមុខងារសាធារណៈ នឹងរៀបចំបោះពុម្ពតារាងទូទាត់បៀវត្សនិងអាណត្តិបើកប្រាក់បៀវត្សខែឧសភា ឆ្នាំ២០១៦ ជូនមន្ត្រីរាជការស៊ីវិលឱ្យបានរួចរាល់ក្នុងសប្តាហ៍ទី១នៃខែឧសភា ឆ្នាំ២០១៦
- ក្រសួងមុខងារសាធារណៈ សូមស្នើសុំក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ អង្គភាពជំនាញ រាជធានី ខេត្ត មេត្តាផ្តល់ឯកសារពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល មកក្រសួងមុខងារសាធារណៈឱ្យបានត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ ក្នុងករណីដែលក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ផ្តល់ឯកសារខាងលើនេះមិនទាន់ពេលវេលា ក្រសួងមុខងារសាធារណៈនឹងបោះពុម្ពតារាងទូទាត់បៀវត្សនិងអាណត្តិបើកប្រាក់បៀវត្សជាស្វ័យប្រវត្តិ
- ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវធានាការបើកផ្តល់ប្រាក់បៀវត្សប្រចាំខែឧសភា ឆ្នាំ២០១៦ ជូនមន្ត្រីរាជការស៊ីវិលរបស់ខ្លួន ឱ្យបានយ៉ាងយូរក្នុងសប្តាហ៍ទី៣នៃខែឧសភា ឆ្នាំ២០១៦។

ក្រសួងមុខងារសាធារណៈ សង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងលោក លោកស្រីប្រធានមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ តាមការគួរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**

- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរនិងអង្គភាពជំនាញរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh